រដ្ឋសភា

# បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១
## អំពីការិយាល័យបណ្តោះអាសន្ន និងការកិច្ច

**ប្រការ ១** :

*រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុង ១ ឆ្នាំ ។*

*សម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិចបីខែ ។*

**ប្រការ ២ ថ្មី** (**ពីរ**) :

*នៅពេលបើកសម័យប្រជុំលើកទី១ នៃនីតិកាលនីមួយៗរដ្ឋសភា ត្រូវចាប់ដំណើរការក្រោមអធិបតីភាពប្រធានបណ្តោះអាសន្នមួយរូប ដែលជាបេក្ខជនជាប់ឆ្នោតមានអាយុច្រើនជាងគេដែលមានវត្តមាន ហើយមានសមាជិកប្រាំរូប ដែលជាបេក្ខជនជាប់ឆ្នោតមាន អាយុតិច ជាងគេដែលមានវត្តមាន ជាលេខាធិការដើម្បីជួយប្រធានក្នុងការងារ ។*

**ក**-*ក្នុងករណីធម្មតា ក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភា ខាងលើនេះ ប្រសិនបើមានកូរ៉ុមលើសពីពាក់កណ្តាលនៃចំនួនសមាជិក រដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្តើមធ្វើការតាមរបៀបវារៈដូចតទៅ* :

**១**-*សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។*

**២**-*បោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុ-ប្រធានទាំងពីររបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួន សមាជិករដ្ឋសភាទាំងមូល ។*

*មិនអាចជជែកពិភាក្សាអ្វីឡើយនៅក្រោមអធិបតីភាពរបស់ព្រឹទ្ធ-*

សមាជិក ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

**ខ**-ក្នុងករណីដែលស្ថានភាពនយោបាយតម្រូវឲ្យអនុវត្តតាមច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិក្រោមការដឹកនាំរបស់ព្រឹទ្ធសមាជិករដ្ឋសភាខាងលើនេះ ប្រសិនបើមានកូរ៉ុម លើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាត្រូវចាប់ផ្តើមធ្វើការតាមរបៀបវារៈដូចតទៅ :

**១**-សម្រេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

**២**-បោះឆ្នោតជាកញ្ចប់ដើម្បីជ្រើសតាំង ប្រធាន អនុប្រធានរដ្ឋសភា ប្រធាន អនុប្រធានគណៈកម្មការជំនាញទាំងអស់នៃរដ្ឋសភា និងផ្តល់សេចក្តីទុកចិត្តចំពោះរាជរដ្ឋាភិបាលនៅដើមនីតិកាលនីមួយៗ ដោយវិធីលើកដៃនិងដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

មិនអាចជជែកពិភាក្សាអ្វីឡើយនៅក្រោមអធិបតីភាពរបស់ព្រឹទ្ធ-សមាជិក ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនពេលចូលកាន់តំណែងដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

# ជំពូកទី ២
# អំពីសុពលភាពនៃអ្នកតំណាងរាស្ត្រ

**ប្រការ ៣ ថ្មី(ពីរ)** :

*នៅពេលបើកសម័យប្រជុំខាងលើនេះ ព្រឹទ្ធសមាជិករដ្ឋសភាប្រកាស ជូនអង្គសភា :*

*-ឈ្មោះបេក្ខជនជាប់ឆ្នោតជាស្ថាពរ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបញ្ជូនមក ។*

*-ឈ្មោះបេក្ខជនជាប់ឆ្នោតដែលមានគេប្តឹងតវ៉ា ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញបានបដិសេធបណ្តឹងទាំងនោះ ។*

*ការប្រកាសសុពលភាពខាងលើនេះ មិនអាចធ្វើបានឡើយក្នុងករណីដែលមានគណបក្សនយោបាយណាមួយទទួលអាសនៈមួយ ឬច្រើនក្នុងរដ្ឋសភាធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូងតាមការកោះប្រជុំរបស់ព្រះមហាក្សត្រឬធ្វើពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភាសម្រាប់ការប្រកាសសុពលភាព នៃអាណត្តិរបស់សមាជិកនីមួយៗ ។*

*ក្នុងករណីនេះព្រឹទ្ធសមាជិករដ្ឋសភាត្រូវចាត់នីតិវិធីតាមបទប្បញ្ញត្តិនៃមាត្រា ១៣៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។*

*ឈ្មោះតំណាងរាស្ត្រទាំងអស់ ដែលបានប្រកាសសុពលភាព រួចហើយត្រូវបិទផ្សាយក្នុងរដ្ឋសភា ផ្សព្វផ្សាយជាសាធារណៈ ក្រោយពេលប្រជុំ និងត្រូវចុះផ្សាយក្នុងរាជកិច្ចក្រោយពីបានធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។*

**ប្រការ ៤ ថ្មី** :

*តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខ នៃព្រះរាជាណាចក្រកម្ពុជា ។*

*តំណាងរាស្ត្រគ្រប់រូប ត្រូវបានទទួលការធានារ៉ាប់រងសង្គម នៅក្នុងអាណត្តិរបស់ខ្លួន ។ ដោយឡែក ក្នុងករណីដែលតំណាងរាស្ត្រទទួលអនិច្ចកម្មនៅក្នុងអាណត្តិ រដ្ឋសភាត្រូវទទួលបន្ទុករៀបចំពិធីបុណ្យសព និងផ្តល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ គ្រប់យ៉ាងដល់គ្រួសារសពរយៈពេលមួយឆ្នាំទៀតគិតពីថ្ងៃទទួលអនិច្ចកម្ម ។*

*គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវរៀបចំរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម របបបេសកកម្ម និងលក្ខខណ្ឌធ្វើការងារ របស់តំណាងរាស្ត្រ ។*

## ជំពូកទី ៣
## អំពីគណៈកម្មាធិការអចិន្ត្រៃយ៍
## និងគណៈកម្មការនានានៃរដ្ឋសភា

**ប្រការ ៥ ថ្មី (ពីរ)** :

*ក្រោយពីព្រះមហាក្សត្រ ឬព្រះរាជតំណាងបានបើកនីតិកាលរដ្ឋសភារួចហើយ ហើយបើអង្គសភាមានសមាជិកវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល រដ្ឋសភាអាចដំណើរការបន្ត តាមរបៀបវារៈដូចមានចែងក្នុងប្រការ ២ ថ្មី (ពីរ) ។*